**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...១៤៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ខេមបូខាន-ស៊ុណ្ណ មេធលលីក មេធៀរៀល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស ខេមបូខាន-ស៊ីណូ មេធលលីក មេធៀរៀល** ដែលមានទីតាំងស្ថិតនៅភូមិឫទ្ធី១ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេស ខេមបូខាន-ស៊ីណូ មេធលលីក មេធៀរៀល** មានទំហំ ៥៥០.០០៨ម$^{២}$ (ប្រាំរយហាសិបពាន់ ប្រាំបីម៉ែត្រការ៉េ) ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ចជាចំណែកភ្ជាប់អនុក្រឹត្យនេះ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស ខេមបូខាន-ស៊ីណូ មេធលលីក មេធៀរៀល** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស ខេមបូខាន-ស៊ីណូ មេធលលីក មេធៀរៀល** នេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និង ក្រុមហ៊ុន ខេមបូឌាន-ស៊ុណ្វ មេធលលីក មេធៀវៀល អ៊ិនដាសស្រ្ទៀល ជាក ឯ.ក ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្តាសោភា**

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រធាន ក.អ.ក
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ប្លង់បង្ហាញទីតាំងដីដែលត្រូវកាត់ចេញពីតំបន់សេដ្ឋកិច្ចពិសេសរបស់ក្រុមហ៊ុន ខេមបូឌាន-ស៊ីណូ ម៉េងឈាង មេគៀងរៀង ស៊ិនជាសស្បៀង ឯ.ក

ភូមិសាស្ត្រស្ថិតនៅភូមិឫទ្ធី១ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

យោងលិខិតលេខ : ២៣៨៦ ដនស/ដសក

ថ្ងៃច័ន្ទ ៧ រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៨

របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់




មាត្រដ្ឋាន : 1:6,000

តារាងនិយាមកានៃបង្គោលប្រើជាពិភាគ

ប្រភព : អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

Projection UTM, Zone48N, Datum WGS84

| Point_ID | Northing (m) | Easting (m) |
|---|---|---|
| 906A | 1201864.858 | 359743.035 |

តារាងនិយាមកាចំណុចព្រំដី

Projection UTM, Zone48N, Datum WGS84

| Point_ID | Northing (m) | Easting (m) |
|---|---|---|
| 1 | 1209216.975 | 360349.430 |
| 2 | 1209509.416 | 360612.119 |
| 3 | 1209124.694 | 361029.300 |
| 4 | 1208658.775 | 361544.728 |
| 5 | 1208584.198 | 361484.729 |
| 6 | 1208465.877 | 361469.574 |
| 7 | 1208246.856 | 361232.730 |
| 8 | 1208215.666 | 361175.563 |
| 9 | 1208226.122 | 361135.633 |
| 10 | 1208655.710 | 361054.713 |
| 11 | 1208682.937 | 360911.492 |

**សញ្ញាសំគាល់**

- • ចំណុចព្រំដី
- ▲ ចំណុចបង្គោលប្រើជាពិភាគ (906A)
- ព្រំដី
- ផ្លូវទទឹង ៥០ ម៉ែត្រ
- ក្បាលដីស្នើសុំ

**ផ្ទៃក្រឡាដីសរុប : ៩៩,០០៨ ហិកតា**

រៀបចំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ

ឧបករណ៍វាស់វែង : O-GPS (Leica UNO)

លេខ : ៤៨៣ មដនសស/២៨១

បានឃើញ និង ឯកភាព

ថ្ងៃ ... ខែ ... ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ព្រះសីហនុ, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៨

**ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ**

**ខេង ស្រ៊ុន**

លេខ : ១១២ ស.ស.ស

បានត្រួតពិនិត្យត្រឹមត្រូវ

គោរពជូនលោកប្រធានមន្ទីរមេត្តាពិនិត្យ-សម្រេច ។

ថ្ងៃ ... ខែ ... ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ស្ទឹងហាវ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៨

**ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីស្រុកស្ទឹងហាវ**

**ស៊ីវុទ្ធ កុសល**

ថ្ងៃ ... ខែ ... ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ស្ទឹងហាវ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៨

**ជាងសំណង់ និងគូសប្លង់**